ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៨៩ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ជូលីស ហាលីម** **(JULIUS HALIM)** ជនជាតិឥណ្ឌូនេស៊ី សញ្ជាតិឥណ្ឌូនេស៊ី ដោយប្តូរឈ្មោះជា **នួន ជេលីន** **(NOUN JAELIN)** ១០៩៩៣

២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៨៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **រីដ អែតឌីសុន ឃើឃីនបៅអើ** **(REID ADDISON KIRCHENBAUER)** ជនជាតិអាមេរិក សញ្ជាតិអាមេរិក ដោយប្តូរឈ្មោះជា **ស៊ីន មករា** **(SIN MAKARA)** ១០៩៩៤

២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៨៧ ស្តីពី ការតែងតាំង និង ផ្តល់ឋានៈ ជាទីប្រឹក្សា និងជំនួយការលោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ៣ រូប ១០៩៩៥

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៨-១២-២០២១ -អនុក្រឹត្យលេខ ២៧២ អនក្រ.បក ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិសំបូរព្រៃគុក ១០៩៩៦

៣១-១២-២០២១ -អនុក្រឹត្យលេខ ៦០៥ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១១០១០

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៤-១១-២០២១ -ប្រកាសលេខ ៧៨៤ សហវ.ប្រក ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ១១០១២

២៤-១១-២០២១ -ប្រកាសលេខ ៧៨៥ សហវ.ប្រក ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ១១០១៦

២៤-១១-២០២១ -ប្រកាសលេខ ៧៩០ សហវ.ប្រក ស្តីពី ការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដាដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធឱ្យសាលាជាតិពន្ធដា ១១០១៩

## ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


២៦-១១-២០២១ -ប្រកាសលេខ ៤២២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខ្មែរ អ៊ិនវេឡិប បង្កើតរោងចក្រ ផលិតស្រោមសំបុត្រ និងសម្ភារៈការិយាល័យ ១១០២៤

២៦-១១-២០២១ -ប្រកាសលេខ ៤២៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីមែកស៍ អេឡិកទ្រិក បង្កើតរោងចក្រ ផ្គុំតម្លើងគ្រង់ស្វូអគ្គិសនី និងសម្ភារៈអគ្គិសនីផ្សេងៗ ១១០២៧

២៩-១១-២០២១ -ប្រកាសលេខ ៤២៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន ណាតស៍ ជ្រេហ្គន ខនគ្រីត ឯ.ក បង្កើតរោងចក្រលាយបេតុង ១១០៣០

២៩-១១-២០២១ -ប្រកាសលេខ ៤២៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១១០៣៣

២៩-១១-២០២១ -ប្រកាសលេខ ៤២៦ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមឃើរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតតង់ និងសម្ភារៈបោះជំរុំគ្រប់ប្រភេទ (កាបូប តុ កៅអី គ្រែ ស៊ុមគ្រែ ទូក្រណាត់ ផ្ទេរ ទោង និងសម្ភារៈផ្សេងទៀត ១១០៣៦


## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


១៨-១-២០២១ -ប្រកាសលេខ ០០០១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការផែចខ្ចប់ឧស្ម័នអិល ភី ជី លេខ ០០០១ រថ.អប្រក.អប ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១០៣៩

៤-១-២០២១ -ប្រកាសលេខ ០០០២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០២ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៤៤

៤-១-២០២១ -ប្រកាសលេខ ០០០៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០០៤ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៤៨

៤-១-២០២១ -ប្រកាសលេខ ០០០៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០០៥ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៥២

៤-១-២០២១ -ប្រកាសលេខ ០០០៦ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០៦ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៥៦

៤-១-២០២១ -ប្រកាសលេខ ០០០៧ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០៧ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៦០

៤-១-២០២១ -ប្រកាសលេខ ០០០៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០០៨ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៦៤

៤-១-២០២១ -ប្រកាសលេខ ០០០៩ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០០៩ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៦៨

៤-១-២០២១ -ប្រកាសលេខ ០០១១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០១១ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១០៧២

| | | |
|---|---|---|
| ៤-១-២០២១ | -ប្រកាសលេខ ០០១២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០១២ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ | ១១០៧៦ |
| ៤-១-២០២១ | -ប្រកាសលេខ ០០១៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០០១៣ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ | ១១០៨០ |
| ១៥-២-២០២១ | -ប្រកាសលេខ ០២១០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២១០ រថ.អប្រក.លអ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១០៨៤ |
| ១៥-២-២០២១ | -ប្រកាសលេខ ០២១៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២១៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១០៨៨ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២២៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២២៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១០៩២ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២២៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២២៨ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១០៩៦ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២៣០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២៣០ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១១០០ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២៣១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២៣១ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១១០៤ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២៤០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២៤០ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១១០៨ |
| ១៧-២-២០២១ | -ប្រកាសលេខ ០២៤២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០២៤២ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ | ១១១១២ |


## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


| | | |
|---|---|---|
| ១៦-៨-២០២១ | -ប្រកាសលេខ ០៩៩ កយ.ប្រក/២១ ស្តីពី ការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ | ១១១១៦ |

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ជូលីស ហាលីម** (JULIUS HALIM) ជនជាតិ ឥណ្ឌូណេស៊ី សញ្ជាតិ ឥណ្ឌូណេស៊ី កើតនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩២ នៅទីក្រុងប៉េម៉ាតាំង សៀនតា សាធារណរដ្ឋឥណ្ឌូណេស៊ី ដោយប្តូរឈ្មោះជា **នួន ជេលីន** ( NOUN JAELIN )។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពសព.២១១៥.៩០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **រីដ អែតឌីសុន ឃើឃីនបៅអើ** ( REID ADDISON KIRCHENBAUER) ជនជាតិ **អាមេរិក** សញ្ជាតិ **អាមេរិក** កើតនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩១ នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ដោយប្តូរឈ្មោះជា **ស៊ីន មករា** ( SIN MAKARA )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៣៧.២០១៤.៩០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការ បោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៥៧ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង ទីប្រឹក្សា និងជំនួយការ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា។
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៤៤៧ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការតែងតាំង ទីប្រឹក្សា និងជំនួយការ លោជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និង ផ្តល់ឋានៈ ជាទីប្រឹក្សា និងជំនួយការ លោជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ៣រូប ៖

ក- តែងតាំងជាទីប្រឹក្សា

១-ឯកឧត្តម **លី ច័ន្ទរង្សី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោកជំទាវ **មិត្ត ចាន់លីនដា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

ខ-តែងតាំងជាជំនួយការ

-លោកជំទាវ **ញឹម ដាលីន** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២១១២, ៩០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៧៧២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិសំបូរព្រៃគុក

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/០៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៥ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិសំបូរព្រៃគុកជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិសំបូរព្រៃគុក ដែលសរសេរកាត់ថា អ.ជ.ស.ព.។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពនៃ អ.ជ.ស.ព.។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

### ផ្នែកទី១

### បេសកកម្ម មុខងារ និងភារកិច្ច

**មាត្រា៣.-**

អ.ជ.ស.ព. បំពេញមុខងារជាសេនាធិការឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើបេសកកម្មដឹកនាំ គ្រប់គ្រង ការពារ ថែរក្សា អភិរក្សនិងអភិវឌ្ឍរមណីយដ្ឋាននៃប្រាសាទសំបូរព្រៃគុក។

**មាត្រា៤.-**

អ.ជ.ស.ព. មានមុខងារនិងភារកិច្ចដូចតទៅ÷

- ការពារ ថែរក្សា អភិរក្ស និងលើកតម្លៃឧទ្យានបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សិក្សារៀបចំ និងអនុវត្តឱ្យបានសម្រេចនូវផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍន៍ទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកប្រកបដោយចីរភាព
- គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ទប់ស្កាត់បទល្មើសព្រៃឈើ និងអំពើអនាធិបតេយ្យនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមតំណាក់កាលនីមួយៗដើម្បីធ្វើឱ្យបានសម្រេចសមិទ្ធផលដែលបានកំណត់ក្នុងផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍន៍ទេសចរណ៍ដូចបានរៀបរាប់ខាងលើ
- រួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយដែលទាក់ទងនឹងបេសកកម្មរបស់ អ.ជ.ស.ព. ដើម្បីការពារនិងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រសួង ស្ថាប័ន មូលនិធិ អង្គការ សមាគមជាតិនិងអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានគោលបំណងស្របនឹងអាជ្ញាធរ ដើម្បីការពារនិងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក
- ចុះកិច្ចព្រមព្រៀងស្តីពីគម្រោង ឬកម្មវិធីនានាជាមួយអង្គការជាតិ និងអន្តរជាតិ
- សហការ និងសម្របសម្រួលជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមានគម្រោងផែនការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និងការផ្តល់សេវាផ្សេងៗ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ផ្នែកទី២
## រចនាសម្ព័ន្ធ

**មាត្រា៥.-**

អង្គភាពប្រត្តិបត្តិរបស់ អ.ជ.ស.ព. មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

២. នាយកដ្ឋានសណ្តាប់ធ្នាប់

៣. នាយកដ្ឋានបុរាណវិទ្យា និងអភិរក្ស

៤. នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ

៥. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

៦. នាយកដ្ឋានបរិស្ថាន។

អ.ជ.ស.ព. មានអង្គភាពសវនកម្មផ្ទៃក្នុងមួយ ជាសេនាធិការលើកិច្ចការសវនកម្ម។

អ.ជ.ស.ព. មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ជាសេនាធិការលើការងារលទ្ធកម្មសាធារណៈ និងគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ជាសេនាធិការលើការងារបញ្ជីសារពើភណ្ឌ ដែលត្រូវបង្កើតអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ អ.ជ.ស.ព. ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

អាជ្ញាធរជាតិសំបូរព្រៃគុក ដឹកនាំដោយអគ្គនាយក ១ (មួយ)រូប និងមានអគ្គនាយករងជាជំនួយការចំនួនច្រើនបំផុត ៥ (ប្រាំ)រូប។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ១ (មួយ)រូប និងមានអនុប្រធានជាជំនួយការ ចំនួនច្រើនបំផុត ៥ (ប្រាំ)រូប។

នាយកដ្ឋាននីមួយៗ មានការិយាល័យមួយចំនួនជាសេនាធិការ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនៃនាយកដ្ឋានចំណុះ អ.ជ.ស.ព. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ប្រធាននាយកដ្ឋាន ត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យចុះក្រោមត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតាមសំណើរបស់អគ្គនាយកអ.ជ.ស.ព. តាមការឯកភាពរបស់ក្រុមប្រឹក្សាភិបាល។

## ជំពូកទី៣
## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា៧.-**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររួមមាន រដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ផែនការ សម្ភារបរិក្ខារ ស្ថិតិនីតិកម្មនិងពិធីការ
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលក្នុងក្របខណ្ឌ អ.ជ.ស.ព. ជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ព្រមទាំងទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិសមត្ថកិច្ចរបស់ អ.ជ.ស.ព.

- គ្រប់គ្រងនិងសម្របសម្រួលការផ្តល់សេវាកម្មរដ្ឋបាលនានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.ជ.ស.ព.
- ពិនិត្យនិងគ្រប់គ្រងការងាររបៀបវារៈមមាន លិខិតចេញចូល ចរាចរលិខិតផ្ទៃក្នុង និងតម្កល់ឯកសារ
- គ្រប់គ្រងនិងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រម លើបុគ្គលិកទាំងអស់របស់ អ.ជ.ស.ព.
- រៀបចំផែនការ ស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិក ព្រមទាំងធ្វើតារាងការងារដែល អ.ជ.ស.ព. បានអនុវត្តកន្លងមក និងត្រូវអនុវត្តបន្តនាពេលអនាគត
- អនុវត្តតាមតារាងកំណត់ប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ការងារនីមួយៗរបស់មន្ត្រីរាជការនិងបុគ្គលិក តាមការកំណត់របស់ប្រធានក្រុមប្រឹក្សាភិបាល
- រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានានូវកម្មវិធី ស្តីពីការកំណត់តំណែងឯកទេសនិងការបែងចែកធនធានមនុស្សនិងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការនិងបុគ្គលិក
- រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេស ពាក់ព័ន្ធនូវសំណើសុំថវិកា ឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់
- តាក់តែងកិច្ចសន្យាគម្រោងវិនិយោគ និងអាជីវកម្មនានា ព្រមទាំងពិនិត្យនិងតាមដាននូវរាល់ការអនុវត្តកិច្ចសន្យា ដើម្បីធានាការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព
- ប្រមូលប្រាក់ចំណូល និងចាត់ចែងចំណាយឱ្យមានតម្លាភាព
- រក្សាទុក និងចាត់ចែងការប្រើប្រាស់មូលនិធិនិងរូបិយវត្ថុ
- គ្រប់គ្រងគេហទំព័ររបស់ អ.ជ.ស.ព.
- គ្រប់គ្រងទ្រព្យសម្ភារគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ទទួលបន្ទុកការងារថែទាំ ជួសជុលអគារការិយាល័យ គ្រឿងបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនរបស់ អ.ជ.ស.ព.
- គ្រប់គ្រង និងផ្គត់ផ្គង់ប្រេងឥន្ធនៈ បរិក្ខារផ្សេងៗជូន អ.ជ.ស.ព.
- ពិនិត្យ និងរៀបចំការងារលទ្ធកម្មសាធារណៈ ដែលពាក់ព័ន្ធការងារផ្គត់ផ្គង់សម្ភារ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ព្រមទាំងសម្រាប់ការងារចាំបាច់បន្ទាន់របស់ អ.ជ.ស.ព.
- សហការជាមួយបណ្តានាយកដ្ឋាននានានៃ អ.ជ.ស.ព. ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- រៀបចំបទដ្ឋានគតិយុត្តនានានិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- សហការក្នុងការរៀបចំព័ត៌មាន ស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការ
- សហការនិងសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន អង្គទូត អង្គការជាតិ និងអង្គការអន្តរជាតិ សមាគមនានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀងនិងគម្រោងស្នើសុំជំនួយ ដើម្បីអភិរក្សនិងអភិវឌ្ឍន៍ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្តល់ជាគុណប្រយោជន៍ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយរដ្ឋបាលខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ ទទួលបន្ទុកលើពិធីការនិងមគ្គុទ្ទេសក៍ទេសចរណ៍ជូនគណៈប្រតិភូជាតិនិងអន្តរជាតិសំខាន់ៗ ដែលអញ្ជើញមករមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំផែនការផ្សព្វផ្សាយអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគក្នុងតំបន់រណប (តំបន់៣)
- រៀបចំ ផែនការស្រាវជ្រាវ និងបណ្តុះបណ្តាលរបស់ អ.ជ.ស.ព. សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធដៃគូជាតិ និងអន្តរជាតិ
- រៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា លើការងារអភិរក្សបេតិកភណ្ឌ និងអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអភិវឌ្ឍធនធានមនុស្ស ដោយសហការជាមួយនាយកដ្ឋាន/អង្គភាពរបស់ អ.ជ.ស.ព. ស្ថាប័នជាតិ និងអន្តរជាតិ
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកនូវលិខិតយុត្តិការបណ្ណសារ
- គ្រប់គ្រងការប្រមូលចំណូល និងទូទាត់ចំណាយរបស់ អ.ជ.ស.ព.
- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ អ.ជ.ស.ព. ស្របតាមគោលនយោបាយយុទ្ធសាស្ត្រដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានកំណត់ និងផែនការសកម្មភាពរបស់ អ.ជ.ស.ព. ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់ អ.ជ.ស.ព.
- ធ្វើការទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិការបស់ អ.ជ.ស.ព.
- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា

- សម្របសម្រួលក្នុងនាមជាលេខាធិការ របស់អគ្គនាយកសម្រាប់ការតាមដាន ត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យ របាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ជូនប្រធានក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ អនុម័ត រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ អ.ជ.ស.ព. ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៤
## នាយកដ្ឋានសណ្តាប់ធ្នាប់

**មាត្រា៨.-**

នាយកដ្ឋានសណ្តាប់ធ្នាប់ មានភារកិច្ចដូចខាងក្រោម៖

- ការពារនិងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- លើកផែនការចាត់ចែងកងកម្លាំងការពារនៅតាមគោលដៅនានាដែលបានកំណត់
- អង្កេត តាមដាន និងទប់ស្កាត់សកម្មភាពល្មើសផ្សេងៗនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឯកសារនិងបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធនឹងបទល្មើសក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកជូនអគ្គនាយក អ.ជ.ស.ព. ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
- សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពពាក់ព័ន្ធ ដើម្បីមានវិធានការទប់ស្កាត់ចំពោះការសាងសង់ដែលគ្មានការអនុញ្ញាត ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដី ការគាស់រុករក ការលួចវត្ថុបុរាណ និងសកម្មភាពដែលបង្កឱ្យខូចខាតដល់រចនាសម្ព័ន្ធប្រាសាទនៅក្នុងប្រាសាទ នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៥
## នាយកដ្ឋានបុរាណវិទ្យា និងអភិរក្ស

**មាត្រា៩.-**

នាយកដ្ឋានបុរាណវិទ្យា និងអភិរក្ស មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការមេ ស្តីពីការគ្រប់គ្រង អភិរក្ស និងថែទាំប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយរួមបញ្ចូលនូវបញ្ជីស្តីពីស្ថានភាពប្រាសាទ ផែនទីចង្អុលកន្លែងគ្រោះថ្នាក់ និងស្ថានភាពនៃការអភិរក្សជាដើម
- រៀបចំកម្មវិធីនិងអនុវត្តការងារអភិរក្សប្រាសាទ ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងចាត់វិធានការបង្ការ ឬសង្គ្រោះស្ថានីយតាមការចាំបាច់
- ស្រាវជ្រាវបេតិកភណ្ឌរូបីនិងអរូបី ព្រមទាំងចងក្រងឡើងវិញស្ថានភាពដើមរបស់ចម្លាក់ និងរចនាសម្ព័ន្ធប្រាសាទ
- ត្រួតពិនិត្យ និងសម្របសម្រួលលើការដ្ឋានអន្តរជាតិនៃកម្មវិធីអភិរក្សប្រាសាទបុរាណ
- ចុះបញ្ជីសារពើភណ្ឌប្រាសាទ និងគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រួមចំណែកក្នុងការធ្វើវិក្រឹតការ ឬបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេស
- ផ្សព្វផ្សាយអំពីតម្លៃបេតិកភណ្ឌនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដល់ប្រជាពលរដ្ឋ
- កំណត់ទីតាំងសម្រាប់ការរៀបចំពិធីផ្សេងៗ ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានា ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៦
## នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ

**មាត្រា១០.-**

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យសំណើសុំសាងសង់ និងរៀបចំលិខិតអនុញ្ញាតសាងសង់ ដោយគោរពនូវតម្លៃបេតិកភណ្ឌ និងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានពិនិត្យការសាងសង់
- សិក្សា និងកំណត់រចនាបថនៃសំណង់ ដែលអាចអនុញ្ញាតឱ្យសាងសង់នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំបែបបទធ្វើបណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លីឱ្យសមស្របជាមួយទិន្នន័យសុរិយោដី និងតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំឯកសារដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឱ្យមានមូលដ្ឋានទិន្នន័យប្រជាសាស្ត្រ ដើម្បីវិភាគ វាយតម្លៃ និងតាមដានការវិវត្តប្រជាសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- តាមដានការប្រែប្រួលកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដើម្បីបង្កើនការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- វិភាគ និងវាយតម្លៃផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគ និងអភិវឌ្ឍន៍ទាំងឡាយក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៧
## នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

**មាត្រា១១.-**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ មានភារកិច្ចដូចតទៅ÷

- កំណត់ទិសដៅ និងផែនការអភិវឌ្ឍទេសចរណ៍នៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ឱ្យស្របទៅនឹងគោលនយោបាយជាតិលើវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល
- ធ្វើស្ថិតិភ្ញៀវទេសចរដែលមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំ និងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ជំរុញផ្សព្វផ្សាយ និងសិក្សាទីផ្សារដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយដៃគូជាតិ និងអន្តរជាតិដែលមានជំនាញក្នុងវិស័យទេសចរណ៍
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំបណ្តុះបណ្តាល និងវិក្រឹតការ មគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំការត្រួតពិនិត្យជាប្រចាំលើគុណភាពសេវាកម្មទេសចរណ៍ នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៨

## នាយកដ្ឋានបរិស្ថាន

**មាត្រា១២.-**

នាយកដ្ឋានបរិស្ថាន មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងសំណល់រឹង គ្រប់គ្រងទឹកទាំងបរិមាណនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងព្រៃឈើនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក រួមមានការអភិរក្ស ការថែទាំ ការដាំកូនឈើឡើងវិញ និងការកំណត់អត្តសញ្ញាណដើមឈើ
- សិក្សាពីរុក្ខជាតិ និងសត្វនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ការពារ និងលើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិដែលមានទំនាក់ទំនងនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរ
- សិក្សានិងតាមដានព័ត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ នៅតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៩
## អង្គភាពសវនកម្មផ្ទៃក្នុង

**មាត្រា១៣.-**

អង្គភាពសវនកម្មផ្ទៃក្នុង ត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

អង្គភាពសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា១៤.-**

មន្ត្រីរាជការក្នុងមុខតំណែងបច្ចុប្បន្ន ត្រូវបានរក្សាទុកនូវមុខងារ ភារកិច្ច និងតួនាទីរបស់ខ្លួនរហូតដល់មានការតែងតាំង ឬប្រគល់ភារកិច្ចថ្មី។

## ជំពូកទី១១
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៥.-**

ចំពោះបុព្វសិទ្ធិ និងសមត្ថកិច្ចរបស់ អ.ជ.ស.ព. ដែលពាក់ព័ន្ធ ឬដែលអាចពាក់ព័ន្ធជាមួយបុព្វសិទ្ធិ និងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នផ្សេងៗទៀត រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួង ស្ថាប័នទាំងនោះ ត្រូវសហការកំណត់ដោយប្រកាសរួម។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា១៦.-**

អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៣៣ អនក្រ.បក. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិសំបូរព្រៃគុក



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២០៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សម្រាប់អាណត្តិឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **សាន ចន្ទ្រនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣- លោក **ហ៊ី ឌីណារត្ន** | ប្រធាននាយកដ្ឋានអប់រំ ការងារ វប្បធម៌ ធម្មការ និងសាសនា នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តមបណ្ឌិត **ហុង ជឿន** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៥- ឯកឧត្តម **អិន អេម** | សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៦- ឯកឧត្តមបណ្ឌិត **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក។ |

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...[illegible]............សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១ .-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិតសភាចារ្យ | **ជួ ចិន្ដា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម | **គង់ ទិបុល** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម | **ធេព ធន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤. | ឯកឧត្តម | **គុយ ម៉ារិនឌី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥. | ឯកឧត្តម | **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. | ឯកឧត្តម | **ហេង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម | **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. | ឯកឧត្តម | **អ៊ុន ចាន់ត្រា** | អគ្គនាយករង នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ៩. | លោក | **ទឹម តុលា** | ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. | លោក | **ទ៉ែត ឆៃលាង** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១. | លោក | **ជ័យ រិទ្ធី** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២. | លោក | **រស់ សារ៉ាត់** | ប្រធានការិយាល័យពន្ធអចលនទ្រព្យ នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៣. | លោក | **សួន សុវណ្ណណៈ** | ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ |
| ១៤. | កញ្ញា | **ឈឺន សុគន្ធា** | អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ។ |

**ប្រការ ២ .-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំគោលនយោបាយ និងគោលការណ៍សម្រាប់កំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច

- កំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមរាជធានី-ខេត្តនីមួយៗ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច។ ក្នុងករណីចាំបាច់ គណៈកម្មការនេះអាចអញ្ជើញស្ថាប័នពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការវាយតម្លៃ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំជាសាធារណៈ ដល់អនុគណៈកម្មការ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ពិនិត្យកែសម្រួលតម្លៃអចលនទ្រព្យ សម្រាប់រយៈពេលកំណត់ណាមួយ តាមការចាំបាច់នៃការប្រែប្រួលថ្លៃអចលនទ្រព្យ
- ចេញសេចក្តីណែនាំ និងសម្របសម្រួលក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន និងត្រួតពិនិត្យការងាររបស់អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យរាជធានី-ខេត្ត។

**ប្រការ ៣ .-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ នៅតាមរាជធានី-ខេត្តនីមួយៗ ដែលមានអភិបាលរាជធានី-ខេត្ត ឬតំណាងជាប្រធាន សម្រាប់ជាជំនួយការអនុវត្តការងារខាងលើនេះ។

អនុគណៈកម្មការនេះ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់។

**ប្រការ ៤ .-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ រាជធានី-ខេត្ត មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ជាជំនួយការ។

ក្រុមការងារឃុំ-សង្កាត់ មានភារកិច្ច ដូចតទៅ ÷

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ច
- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ រាជធានី-ខេត្ត
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារពាក់ព័ន្ធដទៃទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ។

**ប្រការ ៥ .-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ ៦ .-**

ប្រកាសលេខ ១២៥ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧ .-**

សមាសភាពដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៥៥ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៨ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៤៥២ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១ .-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិតសភាចារ្យ | **ជួ ចិដិត្ត** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម | **គង់ ទិបុល** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម | **ធេព ធន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤. | ឯកឧត្តម | **គុយ ម៉ារិនឌី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥. | ឯកឧត្តម | **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. | ឯកឧត្តម | **ហេង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម | **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. | ឯកឧត្តម | **អ៊ុំ មារ៉ូត** | អគ្គនាយករង នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ៩. | លោក | **ខឹម តុលា** | ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. | លោក | **ទ៉ែត ឆៃលាង** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១. | លោក | **ជ័យ រិទ្ធី** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២. | លោក | **រស់ សារ៉ាត់** | ប្រធានការិយាល័យពន្ធអចលនទ្រព្យ នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៣. | លោក | **សួន សុម្ភណៈ** | ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ |
| ១៤. | កញ្ញា | **ឈឹន សុគន្ធា** | អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ។ |

**ប្រការ ២ .-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ច ដូចខាងក្រោម ÷

- បង្កើតបញ្ជីរាយនាមឈ្មោះតំបន់ ឬខណ្ឌ នៃរាជធានី និងក្រុង ស្រុក នៃខេត្ត ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុងមួយម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ។

**ប្រការ ៣ .-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិចាត់តាំងអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅតាមរាជធានី-ខេត្ត ដែលមានអភិបាលរាជធានី-ខេត្ត ឬតំណាងជាប្រធាន សម្រាប់ជំនួយការក្នុងការអនុវត្តភារកិច្ចខាងលើ។

**ប្រការ ៤ .-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញការងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ ៥ .-**

ប្រកាសលេខ ១២៤ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦ .-**

សមាសភាពដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៧២៥០................សហវ ប្រក

## ប្រកាស
## ស្តីពី
## ការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ ឱ្យសាលាជាតិពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នសស្តីពី ខែមីនា ឆ្នាំ២០២០ ចុះថ្ងៃទី៣០ ៤២១/០៣២០/រកត/ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពិការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ ស៊ីពីភ្នាក់ងារសេវាកម្មពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



វិថីលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការមួយ.-**

ប្រការ៩២ ប្រការ៩៥ ប្រការ៩៦ ប្រការ៩៨ និងប្រការ៩៩ នៃជំពូកទី១២ សាលាជាតិពន្ធដារ នៃប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានកែសម្រួល និងបំពេញបន្ថែម ដូចតទៅ÷

### ជំពូកទី១២
### សាលាជាតិពន្ធដារ

**ប្រការ៩២ ថ្មី.-**

សាលាជាតិពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារផ្តល់ចំណេះដឹងទាក់ទិននឹងពន្ធដារជូនមន្ត្រីពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជន រួមទាំងការងារចុះបញ្ជី គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពចំណេះដឹងភ្នាក់ងារសេវាកម្មពន្ធដារ។ សាលាជាតិពន្ធដារមានភារកិច្ចដូចតទៅ÷

- ចូលរួមជាមួយនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ក្នុងការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ នីតិវិធី កម្មវិធី និងស្តង់ដារការងារពាក់ព័ន្ធនឹងការងារសាលាជាតិពន្ធដារ
- បង្កើន និងពង្រឹងសមត្ថភាពធនធានមនុស្សអគ្គនាយកដ្ឋានពន្ធដារ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន តាមរយៈការផ្តល់ចំណេះដឹងទាក់ទិននឹងពន្ធដារ
- សិក្សា ស្រាវជ្រាវ និងជ្រើសរើសមុខវិជ្ជាដើម្បីបញ្ចូលក្នុងកម្មវិធីសិក្សាស្តីពីពន្ធដារ
- រៀបចំ ចងក្រង ប្រមូលព័ត៌មាននិងឯកសារសម្រាប់ការផ្តល់ចំណេះដឹងទាក់ទិននឹងពន្ធដារ
- ជ្រើសរើសគ្រូបង្រៀនសម្រាប់ដំណើរការនៃការបណ្តុះបណ្តាល
- រៀបចំកម្មវិធីប្រឡងវាយតម្លៃលទ្ធផលនិងលើកសំណើប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រ
- ពង្រីង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន សាលា និងអង្គការជាតិនិងអន្តរជាតិក្នុងការផ្តល់ចំណេះដឹងទាក់ទិននឹងពន្ធដារ
- សហការជាមួយនាយកដ្ឋាន អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័ននានា ក្នុងការរៀបចំការងារផ្តល់ចំណេះដឹង និងការងារនានាពាក់ព័ន្ធនឹងពន្ធដារ
- តំណាងឱ្យអគ្គនាយកដ្ឋានពន្ធដារក្នុងការសម្របសម្រួលការងារផ្តល់ចំណេះដឹងទាក់ទិននឹងពន្ធដារ
- បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងសាលា
- ចុះបញ្ជី គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពចំណេះដឹងភ្នាក់ងារសេវាកម្មពន្ធដារ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់សាលា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

**ប្រការ៩៥ ថ្មី.-**

សាលាជាតិពន្ធដារ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាល

២. ការិយាល័យស្រាវជ្រាវ អភិវឌ្ឍកម្មវិធី និងបណ្ណាល័យ

៣. ការិយាល័យបណ្តុះបណ្តាល និងសហប្រតិបត្តិការ

៤. ការិយាល័យសិក្សាធិការ និងគ្រប់គ្រងទូទៅ។

**ប្រការ៩៦ ថ្មី.-**

ការិយាល័យរដ្ឋបាល មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ នីតិវិធីនិងសេចក្តីណែនាំនានា ដែលចាំបាច់ក្នុងផ្នែកបុគ្គលិក និងហិរញ្ញវត្ថុ
- បង្កើតប្រព័ន្ធដើម្បីបែងចែក និងទទួលខុសត្រូវរាល់ឯកសារ លិខិតស្នាមចេញ-ចូលដែលមានប្រភពពីក្នុង និងក្រៅសាលា
- គ្រប់គ្រងថែរក្សា ការពារ ជួសជុលទ្រព្យសម្បត្តិ និងធានាប្រសិទ្ធភាពការងាររដ្ឋបាល ការងារសុវត្ថិភាព និងការងារសង្គមរបស់សាលា
- ទទួលខុសត្រូវបោះពុម្ពសៀវភៅ ឯកសារសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល
- ត្រួតពិនិត្យ ការប្រើប្រាស់មូលនិធិនិងសម្ភារបរិក្ខារ ដែលទទួលបានពីអគ្គនាយកដ្ឋានពន្ធដារ និងប្រភពផ្សេងៗ ដើម្បីធានាឱ្យការប្រើប្រាស់មូលនិធិនិងសម្ភារទាំងនោះបានត្រឹមត្រូវ និងចំទិសដៅ
- លើកគម្រោងស្នើសុំ និងបែងចែកថវិកា កត់ត្រា និងរក្សាទុកបញ្ជិកាគណនេយ្យ លិខិតយុត្តិការផ្សេងៗ ដែលទាក់ទិននឹងចំណូលចំណាយឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា
- បង្កើតប្រព័ន្ធសន្តិសុខសម្រាប់ការពារអគារ និងសម្ភារបរិក្ខាររបស់សាលា
- រៀបចំរចនាសម្ព័ន្ធសម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រអាទិភាព និងគោលដៅនានាក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន
- គ្រប់គ្រងថែរក្សា និងធ្វើទំនើបកម្មជាប្រចាំនូវកុំព្យូទ័រនិងគ្រឿងបំពាក់ផ្សេងៗ ដែលពាក់ព័ន្ធជាមួយគ្រឹះស្ថានសិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មានដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការធ្វើទំនើបកម្មប្រព័ន្ធកុំព្យូទ័រ
- គាំទ្រដល់ការអភិវឌ្ឍ និងការថែរក្សាទិន្នន័យបណ្តុះបណ្តាលបុគ្គលិក
- គាំទ្រដល់ការបញ្ចូលការសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដូចជាការសិក្សាពីចម្ងាយតាមអ៊ិនធើណេត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូននាយកសាលា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់នាយកសាលា។

**ប្រការ៩៨ ថ្មី.-**

ការិយាល័យបណ្តុះបណ្តាល និងសហប្រតិបត្តិការ មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ នីតិវិធីនិងសេចក្តីណែនាំនានា ដែលចាំបាច់ក្នុងផ្នែកបណ្តុះបណ្តាល
- រៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ ដើម្បីលើកសំណើជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារពិនិត្យនិងសម្រេច
- រៀបចំវគ្គសិក្សាជំនាញពន្ធដារសម្រាប់មន្ត្រីពន្ធដារថ្មី

- វាយតម្លៃលើលទ្ធផលនៃការសិក្សា និងការប្រតិបត្តិរបស់មន្ត្រីពន្ធដារថ្មី ដើម្បីលើកសំណើជូនអគ្គនាយកដ្ឋានពន្ធដារក្នុងការបែងចែកមន្ត្រី
- រៀបចំវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងពន្ធដារជាប្រចាំជូនដល់មន្ត្រីដែលកំពុងបម្រើការងារ
- សិក្សាស្រាវជ្រាវស្តីពីតម្រូវការបណ្តុះបណ្តាលមន្ត្រីពន្ធដារ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល
- រៀបចំសិក្ខាសាលាដើម្បីផ្តល់ចំណេះដឹងនិងបទពិសោធន៍ថ្មីៗទាក់ទិននឹងពន្ធដារ
- រៀបចំវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងពន្ធដារជូនដល់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ
- រៀបចំសិក្ខាសាលា ដើម្បីលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងពន្ធដារ ជូនដល់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ
- ធ្វើការសម្របសម្រួល និងសហប្រតិបត្តិការជាមួយនឹងអង្គភាពនានាក្នុងនិងក្រៅប្រទេស ដែលទាក់ទិននឹងកិច្ចការរបស់សាលាជាតិពន្ធដារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូននាយកសាលា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់នាយកសាលា។

**ប្រការ៩៩ ថ្មី.-**

ការិយាល័យសិក្សាធិការ និងគ្រប់គ្រងទូទៅមានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ នីតិវិធីនិងសេចក្តីណែនាំនានា ដែលចាំបាច់ក្នុងផ្នែកសិក្សា និងការគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារ
- ទទួលខុសត្រូវលើការងាររៀបចំគោលការណ៍ នីតិវិធី និងអនុវត្តការប្រឡងជំនាញវិជ្ជាជីវៈពន្ធដារ
- រៀបចំលិខិតជូនដំណឹងស្តីពីការទទួលពាក្យចូលរៀនតាមវគ្គបណ្តុះបណ្តាល និងជំនាញនីមួយៗរបស់សាលា
- ទទួល និងរក្សាទុកពាក្យស្នើសុំចុះឈ្មោះចូលរៀនសិស្ស-និស្សិត និងសិក្ខាកាមតាមវគ្គ និងជំនាញនីមួយៗ
- គ្រប់គ្រងទិន្នន័យ សិស្ស-និស្សិត និងសិក្ខាកាម ដែលសិក្សានៅសាលាជាតិពន្ធដារ
- រៀបចំប័ណ្ណសម្គាល់ លិខិតបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុ និងវិញ្ញាបនបត្រជូនសិក្ខាកាម
- សម្របសម្រួលកិច្ចការទូទៅពាក់ព័ន្ធជាមួយនឹងការសិក្សានៅសាលាជាតិពន្ធដារ របស់មន្ត្រីពន្ធដារ សិក្ខាកាម និងសិស្ស-និស្សិត ដូចជាការសុំច្បាប់ ការប្តូរវេនសិក្សា និងការព្យួរការសិក្សាជាដើម
- ទទួលខុសត្រូវក្នុងការជ្រើសរើស ការបណ្តុះបណ្តាល និងការគ្រប់គ្រងលើគ្រូឧទ្ទេសនាម (ខាងក្នុងនិងខាងក្រៅសាលា)
- ទទួល និងរក្សាទុកសំណុំឯកសារគ្រូឧទ្ទេសនាម រួមមានប្រវត្តិរូប ឯកសារពាក់ព័ន្ធនានា និងរៀបចំបែងចែកតាមមុខវិជ្ជាដែលទទួលខុសត្រូវ
- ចុះបញ្ជី បច្ចុប្បន្នភាពព័ត៌មាន និងគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារ
- គ្រប់គ្រងការបោះពុម្ព និងផ្តល់អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ
- លើកសំណើជូនថ្នាក់ដឹកនាំ នូវការធ្វើបច្ចុប្បន្នភាពចំណេះដឹងជូនភ្នាក់ងារសេវាកម្មពន្ធដារ
- លើកសំណើជូនថ្នាក់ដឹកនាំក្នុងការសម្រេចផ្តល់ការលើកទឹកចិត្ត ឬដាក់ចេញនូវទណ្ឌកម្មរដ្ឋបាលនានាចំពោះភ្នាក់ងារសេវាកម្មពន្ធដារ

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូននាយកសាលា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់នាយកសាលា។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥ រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២១

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤៤៨ ឧវបន.ប្រក

ថ្ងៃ សៅរ៍ ៧កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៥៨/១៥ គ.វ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតស្រោមសំបុត្រ និងសម្ភារៈការិយាល័យ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខ្មែរ អ៊ិនវេឡិប

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខ្មែរ អ៊ិនវេឡិប (**KHMER ENVELOPE CO., LTD.**) តំណាងដោយលោក **KAJIWARA MASASHI** សញ្ជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខ TZ1112990 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ បង្កើតរោងចក្រផលិតស្រោមសំបុត្រ និងសម្ភារៈការិយាល័យ ដែលមានទីតាំងស្ថិតនៅភូមិដីក្រហម ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ស្រោមសំបុត្រ ( Folding Paper) និងសម្ភារៈការិយាល័យ (ក្រណ្ឌា) | ១៧០៩ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។
ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតស្រោមសំបុត្រ និងសម្ភារៈការិយាល័យ ខ្មែរ អ៊ិនវេឡិប** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៥១ ឧស.កឧ.ប្រក.០៤ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តបាត់ដំបង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុភា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តបាត់ដំបង
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តបាត់ដំបង
- រដ្ឋបាលស្រុកកំរៀង
- រដ្ឋបាលឃុំតាសែន
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៩០/១៨ គ.វ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផ្គុំតម្លើងគ្រង់សូអគ្គិសនី និងសម្ភារៈអគ្គិសនីផ្សេងៗ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន អ៊ីមែកស៍ អេឡិកទ្រីក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **អ៊ីមែកស៍ អេឡិកទ្រីក (EMAX ELECTRIC CO., LTD.)** តំណាងដោយលោក **ឈឹម គឹមឈន** សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ010176605 (01) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ បង្កើតរោងចក្រផ្គុំតម្លើងគ្រង់សូអគ្គិសនី និងសម្ភារៈអគ្គិសនីផ្សេងៗ ដែលមានទីតាំងស្ថិតនៅភូមិសារវ៉ែន ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១- ត្រង់ស្វូ | ២៧១០ |
| ២- សម្ភារៈអគ្គិសនី | ២៧៤០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផ្គុំតម្លើងត្រង់ស្វូអគ្គិសនី និងសម្ភារៈអគ្គិសនីផ្សេងៗ អ៊ីមែកស៍ អេឡិកទ្រីក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០០៩ ឧស.កឧ.ប្រក.០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលិខិតលេខ០៧៨២ ឧវបន.កឧ.លស.០២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តពោធិ៍សាត់ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តពោធិ៍សាត់
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តពោធិ៍សាត់
- រដ្ឋបាលស្រុកក្រគរ
- រដ្ឋបាលឃុំស្នាអន្សា

"ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ...

ថ្ងៃ... ខែ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេមបូឌាន ណតស៍ ដ្រេហ្គន ខនគ្រីត ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន ណតស៍ ដ្រេហ្គន ខនគ្រីត ឯ.ក (**CAMBODIAN NORTH DRAGON CONCRETE CO., LTD.**) តំណាងដោយលោក **LIU, HU** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **E94357228** ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ បង្កើតរោងចក្រលាយបេតុង ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ៨ ផ្លូវបេតុង ភូមិត្រពាំងស្វាយ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| បេតុងលាយស្រេច | ២៣៩៥ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រលាយបេតុង ខេមបូឌាន ណតស៍ ជ្រេហ្គន ខនគ្រីត ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២១៩ ឧស.កឧ.ប្រក.០៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌសែនសុខ
-រដ្ឋបាលសង្កាត់គោកឃ្លាង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ...[illegible]... ខែ...[illegible]... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៥... ខែ...វិច្ឆិកា... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២១៥៦/០៦ គ.វ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការវិនិយោគលើគំរោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា)

## ស ម្រេ ច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) **(NEW MINGDA (CAMBODIA) CO., LTD.)** តំណាងដោយលោក **DONG, AIKANG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ**EH2317359** ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅភូមិឈូកញ្ញុង សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ញូ មីងដា (ខេមបូឌា) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៣២៧ ឧស.កឧ.ប្រក.០៧ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឋ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុភា

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- រដ្ឋបាលសង្កាត់ចោមចៅទី១
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤៤៦ ឧ.វ.ក ស.ប្រក

ថ្ងៃ អង្គារ ១០រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣០២៨/២១ គ.វ.ក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតតង់ និងសម្ភារៈបោះជំរំគ្រប់ប្រភេទ (កាបូប តុ កៅអី គ្រែ ស៊ុមគ្រែ ទូក្រណាត់ ធ្នើរ ទោង និងសម្ភារៈផ្សេងទៀត...) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតតង់ និងសម្ភារៈបោះជំរំគ្រប់ប្រភេទ (កាបូប តុ កៅអី គ្រែ ស៊ុមគ្រែ ទូក្រណាត់ ធ្នើរ ទោង និងសម្ភារៈផ្សេងទៀត...) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេមឃីភើរ (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខេមឃីភើរ (ខេមបូឌា) ឯ.ក **(KAMPKEEPER (CAMBODIA) CO., LTD.)** តំណាងដោយលោក **XIAO, ZHIQIANG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ E70568259 ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ បង្កើតរោងចក្រផលិតតង់ និងសម្ភារៈបោះជំរំគ្រប់ប្រភេទ (កាបូប តុ កៅអី គ្រែ ស៊ុមគ្រែ ទូក្រណាត់ ធ្នើរ ទោង និងសម្ភារៈផ្សេងទៀត...) ដែលមានទីតាំងស្ថិតនៅភូមិស្រែជំរៅ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| តង់ និងសម្ភារៈបោះជំរំគ្រប់ប្រភេទ | ១៣៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតតង់ និងសម្ភារៈបោះជំរំគ្រប់ប្រភេទ ខេមឃីភើរ (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុគា**

<u>ចម្លងជូន៖</u>
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- -រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- -រដ្ឋបាលសង្កាត់ចោមចៅទី២
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
Ministry of Mines and Energy
លេខៈ ០០០១ រ៉ែ. អប្រក.ប្រក.

# ប្រកាស
## ស្ដីពី
## លក្ខខណ្ឌនៃអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី
## លេខ ០០០១ រ៉ែ. អប្រក.អ.ប ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញសំណើសុំ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់លោក ឡាយ យុវណេង
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី សម្រាប់ក្រុមហ៊ុន **អេនើជី ជ្យាយអិន & ត្រេឌីង (ENERGY GIANT & TRADING CO., LTD.)** ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ: ០០០១៩៦៣៩ និងមានទីស្នាក់ការស្ថិតនៅផ្ទះលេខ ៧២ DE1 ផ្លូវលេខ ១១៣ សង្កាត់បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ "អ្នកទទួលបានអាជ្ញាបណ្ណ" ដើម្បីសន្និធិឧស្ម័នអិល ភី ជី ធ្វើប្រតិបត្តិការ និងថែទាំទីតាំងសម្រាប់ការវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ដែលមានទីតាំងស្ថិតនៅភូមិពងទឹក ឃុំដំណាក់រាំង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

**ប្រការ២ .-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពធុរកិច្ច ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ (**ធុរកិច្ចដែលអនុញ្ញាត**)។ ក្នុងករណីអ្នកទទួលបានអាជ្ញាបណ្ណមានបំណងធ្វើធុរកិច្ចផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតដោយឡែកសម្រាប់សកម្មភាពដោយឡែក និងត្រូវស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងៗស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣ .-**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំ និងទទួលបានអាជ្ញាបណ្ណ និង/ឬ លិខិតអនុញ្ញាតផ្សេងៗ ពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមការតម្រូវនៃច្បាប់ជាធរមាន ដើម្បីអនុវត្តកាតព្វកិច្ចនានាដូចមានចែងក្នុងអាជ្ញាបណ្ណនេះ។

**ប្រការ៤ .-**

ប្រកាសនេះ មានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ.០០០១៩៦ អមស. អប ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ និងអាចពន្យារបន្តបាន ស្របតាមអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៥.-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចតទៅ៖

**១. កាតព្វកិច្ចគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

១.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។ ក្នុងករណីមិនទាន់មានបទដ្ឋានរបស់ក្រសួងរ៉ែ និងថាមពល អ្នកទទួលបានអាជ្ញាបណ្ណត្រូវធានាអនុវត្តតាមបទដ្ឋាន



៥៤

បច្ចេកទេសសុវត្ថិភាពដែលជាទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ ក្នុងការសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី។

១.២ អ្នកទទួលបានអាជ្ញាបណ្ណត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងនីតិវិធីនានា ដែលក្រសួងរ៉ែ និងថាមពល សម្រេចដាក់ឱ្យអនុវត្តសម្រាប់កិច្ចដំណើរការសាងសង់ និងធ្វើប្រតិបត្តិការទីតាំងសម្រាប់ការវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី។

១.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា។

១.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវគោរពនិងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននានារបស់ព្រះរាជាណាចក្រកម្ពុជា។

**២. កាតព្វកិច្ចក្នុងការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី**

២.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធ្វើការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី នៅលើទីតាំងដែលបានកំណត់។

២.២ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធ្វើការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី តាមផែនការគំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ដែលមានការយល់ព្រមពីក្រសួងរ៉ែ និងថាមពល។ ក្នុងករណីមានការកែប្រែផែនការគំនូសប្លង់ផ្សេងៗ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវស្នើសុំការយល់ព្រមពីក្រសួងរ៉ែ និងថាមពល មុនចាប់ផ្តើមការរៀបចំ។

២.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។

២.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់នូវរបាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី នេះ ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី ១ នៃត្រីមាសបន្ទាប់។

២.៥ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលដំណើរការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។

២.៦ អ្នកទទួលបានអាជ្ញាបណ្ណ មិនត្រូវប្រគល់ ឬ ផ្ទេរសិទ្ធិបង្កើតទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី នេះឱ្យអ្នកដទៃដោយគ្មានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពលឡើយ។

**៣. កាតព្វកិច្ចផ្សេងទៀត**

៣.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់ប្លង់បច្ចេកទេសជាក់ស្តែងនៃសំណង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ក្រោយសាងសង់រួចជាស្ថាពរមួយច្បាប់សម្រាប់តម្កល់នៅអគ្គនាយកដ្ឋានប្រេងកាត។

៣.២ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យឧស្ម័នអិល ភី ជី ដែលបាននាំចូល និងលក់ចែកចាយជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំក្នុងខែមករា នៃឆ្នាំបន្ទាប់មកក្រសួងរ៉ែ និងថាមពល។

៣.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការទីតាំងសម្រាប់វេចខ្ចប់ (បញ្ចូល) ឧស្ម័នអិល ភី ជី របស់ខ្លួន។

៣.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ដើម្បីឱ្យការគ្រប់គ្រងទីតាំងសម្រាប់វេចខ្ចប់ (បញ្ចូល) ឧស្ម័ន អិល ភី ជី មានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៦.-**

បន្ទាប់ពីទីតាំងវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ត្រូវបានសាងសង់រួចហើយនោះ ម្ចាស់ទីតាំងត្រូវរៀបចំកែសម្រួលទៅតាមលក្ខខណ្ឌដែលតម្រូវដោយក្រសួងរ៉ែ និងថាមពល និងត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដំណើរការទីតាំងវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ពីក្រសួងរ៉ែ និងថាមពល។

**ប្រការ ៧.-**

ដោយប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ពុំទាន់មានចែងពីកម្រៃសេវាសាធារណៈដែលត្រូវបង់ សម្រាប់អាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់វេចខ្ចប់ (បញ្ចូល) ឧស្ម័នអិល ភី ជី អ្នកទទួលបានអាជ្ញាបណ្ណនឹងតម្រូវឱ្យបង់កម្រៃសេវាសាធារណៈក្រោយមានការចែងពីកម្រៃសេវានេះ។

**ប្រការ ៨.-**

អាជ្ញាបណ្ណនេះ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌ ប្រសិនបើអ្នកទទួលបានអាជ្ញាបណ្ណមិនបានចាប់ផ្តើមសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជីនេះ ក្នុងរយៈពេល១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ ឬ អ្នកទទួលបានអាជ្ញាបណ្ណបានប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ៩.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុន **អេនើជី ដ្យាយអិន & ត្រេឌីង** ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចទទួលបន្ទុករៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

ថ្ងៃ ចន្ទ ៥កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០០០៧ រថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០០០៧ រថ.អប្រក.លអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ របស់លោក ព្រហ្ម ម៉ៅ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានយីហោឈ្មោះ ដេប៉ូតេលា ម៉ៅ ម៉ាលីន ស្ថិតនៅភូមិក្រាំងម្កាក់ ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ របស់លោក ព្រហ្ម ម៉ៅ (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តកំពង់ស្ពឺ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. មិនអនុញ្ញាតឱ្យមានការបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈដាក់បីដុងជ័រក្នុងបរិវេណស្ថានីយ

៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងបានតែមួយប្រភេទប៉ុណ្ណោះ

៤. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៥. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៦. ត្រូវរៀបចំឱ្យមានគន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ
៧. ត្រូវរៀបចំឱ្យមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តផ្ទេរប្រេងឥន្ធនៈ
៨. ត្រូវរៀបចំឱ្យមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.–**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០០០៧.រ៉ែ.អប/បក.លអ......ចុះថ្ងៃទី.......០៤.........ខែ...មករា.....ឆ្នាំ២០២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០០០៧.រ៉ែ.អប/បក.លអ ចុះថ្ងៃទី....០៤.......ខែ...មករា.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ.....១០រោច...ខែ...បុស្ស.....ឆ្នាំជូត..ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៤...ខែ..មករា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ-សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ស្ពឺ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
Ministry of Mines and Energy
លេខ: ០០០៤ រ៉ែ-អបក.ប្រក.

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
# លេខ ០០០៤.រ៉ែ:អបក:លអ.....ចុះថ្ងៃទី....០៤.....ខែ...មករា....ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់លោក **ភោគ គឹមសាន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានយីហោ **លឹម លុង ព្រែកតាទែន** ស្ថិតនៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ របស់លោក **ភោគ គឹមសាន** (ម្ចាស់ស្ថានីយ)។

**ប្រការ២.**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធររាជធានីភ្នំពេញ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានការបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈដាក់បីដុងក្នុងបរិវេណស្ថានីយ
២. ពោងឧស្ម័នឥន្ធនៈ គួរមានចំណុះមិនលើសពី ១០ តោន
៣. ពោងឧស្ម័នឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រ ពីពោងប្រេងឥន្ធនៈ
៤. ត្រូវសង់របងជាសំណាញ់ដែកក្រឡាធំ ឬជាចម្រឹងដែកការពារព័ទ្ធជុំវិញពោងឧស្ម័នឥន្ធនៈ
៥. ពោងប្រេងឥន្ធនៈ ដែលមានសំបកតែមួយស្រទាប់ ត្រូវកប់ក្នុងរាងដែលធ្វើពីបេតុងអាមេ មិនជ្រាបទឹក ឬ ប្រេង
៦. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៧. ទុយោចាក់ប្រេងឥន្ធនៈត្រូវមានប្រវែងមិនលើសពី ៦ ម៉ែត្រ
៨. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៩. ត្រូវរៀបចំឱ្យមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១០. ត្រូវរៀបចំឱ្យមានឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់
១១. ត្រូវរៀបចំឱ្យមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥...**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦...**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧...**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងនិងឧស្ម័នឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨...**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០០០៤ រ.ថ.អ.ប៉.ក.ណអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២១ របស់ក្រសួងរ៉ែនិងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០០០៤ រ.ថ.អ.ប៉.ក.ណអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២០ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៦រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៤ រ៉ែ.អឧក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ
លេខ..០០០៤ រ៉ែ.អឧក.លអ.....ចុះថ្ងៃទី....០៤.....ខែ..មករា....ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់លោក **ភោគ គឹមសាន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈយីហោ LHR **ផល្លិការ ចំរើនផល** ស្ថិតនៅភូមិចំរើនផល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ របស់លោក **ភោគ គឹមសាន** (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានជញ្ជាំង បិទជិតនៅជុំវិញពោងឧស្ម័នឥន្ធនៈ ដាក់លើដី
២. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ម៉ែត្រ ពីអគារការិយាល័យ
៣. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពីទូចាក់ប្រេងឥន្ធនៈ
៤. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពីកបំពង់ទទួលប្រេងឥន្ធនៈ
៥. ពោងឧស្ម័នឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ពីបំពង់ខ្យល់ប្រេងឥន្ធនៈ
៦. ពោងឧស្ម័នឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពី របងព្រំដីស្ថានីយប៉ែកខាងកើត
៧. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ពី របងព្រំដីស្ថានីយប៉ែកខាងត្បូង
៨. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពីកបំពង់ទទួលប្រេងឥន្ធនៈ
៩. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពីមាត់កបំពង់ទទួលឧស្ម័នឥន្ធនៈ
១០. ត្រូវមានអាងសម្រាប់ដាក់ពោងប្រេងឥន្ធនៈ
១១. ទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ពីអគារការិយាល័យ
១២. ទុយោចាក់ប្រេង និងឧស្ម័នឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
១៣. ត្រូវមានគន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេង និងឧស្ម័នឥន្ធនៈនីមួយៗ
១៤. ត្រូវមានចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ
១៥. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពក្នុងស្ថានីយឱ្យបានគ្រប់គ្រាន់ និងផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១៦. ត្រូវមានឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់
១៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥...**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦...**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពល មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧...**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-.**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-.**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-.**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-.**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.000៤ រ៉ែ.អ.បក.ឈអ..........ចុះថ្ងៃទី.....០៤.............ខែ...មករា......ឆ្នាំ២០២១........... របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ000៤ រ៉ែ.អ.បក.ចុះលអ ថ្ងៃទី.......០៤.....ខែ.....មករា.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ.....៦រោច...ខែ.បុស្ស....ឆ្នាំជូត.ទោស័ក.ព.ស.២៥៦៤.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៤...ខែ.មករា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: 0003 រ៉ថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ 0003 រ៉ថ.អប្រក.លអ ចុះថ្ងៃទី 04 ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់លោក **ឈួម ផៃណារិន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ដេប៉ូតេលា ឈួម ផៃណារិន** ស្ថិតនៅភូមិកំពីងពួយ ឃុំភ្នំជី ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ របស់លោក **ឈួម ផៃណារិន (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ

២. មិនអនុញ្ញាតឱ្យមានការស្តុកទុក និងតាំងលក់ឥវ៉ាន់ដោយគ្មានសណ្តាប់ធ្នាប់ក្នុងទីធ្លាស្ថានីយ

៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៤. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈពីរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ



៥ ៧

៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីព្រំដីស្ថានីយ
៦. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយក្នុងទីធ្លាស្ថានីយ
៧. ទុយោចាក់ប្រេងមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៩. ត្រូវបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់
១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ និងស្លាកសញ្ញាបម្រាមឱ្យបានគ្រប់គ្រាន់
១១. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ*0003 រ.ផ:អប/ថក.លអ*..........ចុះថ្ងៃទី.......*0.4*..........ខែ...*មករា*......ឆ្នាំ២០*២១*.............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ*0003 រ.ផ:អប/ថក.លអ* ចុះថ្ងៃទី.....*0.4*.....ខែ.....*មករា*.......ឆ្នាំ២០*២១*...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបន្ទាយមានជ័យ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ*ចន្ទ*.....*៦រោច*...ខែ.*បុស្ស*......ឆ្នាំ*ជូត*..*ទោស័ក*ព.ស.២៥៦*៤*
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..*០៤*..ខែ..*មករា*..ឆ្នាំ២០*២១*

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៧ រ៥.អប្រក.ប្រក

# ប្រកាស
## ស្ដីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០០០៧ រ៥.អប្រក.លអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ របស់លោកស្រី មាន ចាន់និត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោ ដេប៉ូតេលារ៉ូ ចាន់និត ស្ថិតនៅភូមិអូរស្វស្តី ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ របស់លោកស្រី មាន ចាន់និត (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. មិនអនុញ្ញាតឱ្យលក់ឥវ៉ាន់ ដោយគ្មានសណ្តាប់ធ្នាប់ក្នុងបរិវេណស្ថានីយ

៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៤. មិនត្រូវបំពាក់វ៉ាន បិទ បើកនៅជាប់នឹងតួបំពង់ខ្យល់



៥៧

៥. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ម៉ែត្រ ពីអគារ

៦. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ម៉ែត្រ

៧. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ

៨. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៩. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ និងត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

១០. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១**.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០០០៧..រ៉ែ.អបែក.ណអ........ចុះថ្ងៃទី.......០៤..........ខែ..មករា.......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២**.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២(ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០០០៧.រ៉ែ.អបែក..ចុះណអ ថ្ងៃទី.....០៤......ខែ..មករា..........ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ.....៦កើត...ខែ..បុស្ស......ឆ្នាំ.ជូត...ទោស័ក.ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៤...ខែ..មករា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៨ រ៥.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០០០៨ រ៥.អប្រក.ប្រក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយស្តុកប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
